ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខៈ ៧១៣/២០ គ.ជ.ប.ជ

# របាយការណ៍ខែតុលា
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងទិសដៅខែវិច្ឆិកា ឆ្នាំ២០២០

## I. ស្ថានភាពទូទៅ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត បានបន្តសកម្មភាព របស់ខ្លួនទៅតាមទិសដៅគ្រោងទុក បើទោះបីជាបាននិងកំពុងតែប្រឈមនឹងសភាពការណ៍វិវត្តថ្មី ដែលមិនអាចប៉ាន់ស្មានបាន ពាក់ព័ន្ធនឹងស្ថានភាពប្រែប្រួលនៃសេដ្ឋកិច្ចពិភពលោក និងបន្ថែមដោយវិបត្តិនៃការរាតត្បាតដោយជំងឺកូវីដ១៩។

ក្រសួង ស្ថាប័ន និងរាជធានី ខេត្ត បានបន្តទិសដៅការងារ ផ្តោតការយកចិត្តទុកដាក់បន្ថែម ទៅលើបញ្ហាវិបត្តិកូវីដ១៩ ដែលជាភាពប្រឈមថ្មី និងដែលជះឥទ្ធិពលដល់ការអនុវត្តសកម្មភាពគ្រប់វិស័យ ធ្វើឱ្យរាំងស្ទះដោយអន្លើ និងត្រូវបន្ថែមភារកិច្ច ក្នុងការដោះស្រាយទប់ស្កាត់ផលប៉ះពាល់ លើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេសអ្នកដែលវិលត្រឡប់ពីប្រទេសក្រៅ ដែលមានចំនួនច្រើនលើសលប់ និងភាគច្រើន ជាអ្នកដែលខ្វះលទ្ធភាព ក្នុងការទ្រទ្រង់ជីវភាព ហើយងាយរងគ្រោះ។ ការជួយសង្គ្រោះពលករដែលវិលត្រឡប់មកពីក្រៅប្រទេស គឺជាកិច្ចការចាំបាច់ ដើម្បីបង្ការទប់ស្កាត់ ការនាំចូលជំងឺកូវីដ១៩ ទៅក្នុងសហគមន៍ និងការដោះស្រាយភាពប្រឈមក្នុងពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ ព្រមទាំងទប់ស្កាត់ការចាញ់បោកមេខ្យល់ ក្នុងការនាំពលករត្រឡប់ទៅប្រទេសគោលដៅវិញ ក្នុងស្ថានភាពដែលមានការរឹតបន្តឹងពីប្រទេសគោលដៅ ដើម្បីការពារជំងឺរាតត្បាត និងវិបត្តិសេដ្ឋកិច្ចដែលកើតមានទូទាំងពិភពលោក ដែលធ្វើឱ្យពលករខាតបង់រឹតតែធ្ងន់ធ្ងរ និងធ្លាក់ទៅក្នុងរលកថ្មីនៃអំពើជួញដូរមនុស្ស។

អាជ្ញាធរ សមត្ថកិច្ច និងលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ និងអង្គការដៃគូ បានធ្វើសកម្មភាពយ៉ាងមមាញឹក ប្រចាំការនៅតាមព្រំដែនទទួលសង្គ្រោះពលករ ដែលវិលត្រឡប់តាមច្រកមិនផ្លូវការ ទាំងយប់ទាំងថ្ងៃ ពិនិត្យកម្តៅ និងផ្តល់សេវាសុខភាព អនុវត្តគោលការណ៍ចត្តាឡីស័កតាមវិធានសុខាភិបាល ផ្តល់អាហារ ត្រៀមមធ្យោបាយដឹកជញ្ជូន ឱ្យបានដល់លំនៅដ្ឋាន និងបន្តតាមដានស្ថានភាពសុខភាព ជីវភាព និងផ្តល់សេវាតាមតម្រូវការផ្សេងៗ និងបន្តតាមដានស្ថានភាព នៅពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ដែលពួកគាត់រស់នៅ។ លើសពីនេះទៅទៀត វិធានការអប់រំ បង្ការទប់ស្កាត់សកម្មភាពវិលត្រឡប់ទៅប្រទេសថៃវិញ ក្នុងអំឡុងពេលដែលមានការរឹតបន្តឹង ពីប្រទេសគោលដៅក្នុងវិធានការទប់ស្កាត់វិបត្តិកូវីដ១៩ និងដោះស្រាយវិបត្តិសេដ្ឋកិច្ច ការបង្កើនការស៊ើបអង្កេតរកមេខ្យល់ជួញដូរមនុស្ស ក្នុងដំណាក់កាលនេះ ការផ្តល់សេវាជួយជនរងគ្រោះ និងជនងាយរងគ្រោះ ត្រូវបានធ្វើឡើងកាន់តែសកម្ម។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួល ពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ អន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារ ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

#### ក.១. ការកសាងច្បាប់

- ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី បានដឹកនាំធ្វើសេចក្តីព្រាងច្បាប់ ស្តីពី"ការពពោះជំនួស"។
- ក្រសួងយុត្តិធម៌ ៖
  - រដ្ឋសភាបានអនុម័តច្បាប់ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ" (MLA) (ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការណ៍ជាប្រញាប់ ដោយព្រះរាជក្រមលេខ នស/រកម ០៦២០/០២០ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០)។
  - បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពី "ការប្រឆាំងអំពើរត់ពន្ធមនុស្ស"។

#### ក.២. សន្ធិសញ្ញា

- ក្រសួងយុត្តិធម៌
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសឡាវ បារាំង និងប្រទេសកូរ៉េខាងត្បូង ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ"
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសអង់គ្លេស ប៉េរូ និងប្រទេសឡាវ ស្តីពី "ការបញ្ជូនទណ្ឌិត"។

#### ក.៣. គោលនយោបាយ និងអនុស្សរណៈនៃការយោគយល់គ្នា

- ក្រសួងទេសចរណ៍ ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាព ជាមួយអង្គការ Friends International។

#### ក.៤. លិខិតបទដ្ឋានគតិយុត្ត

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖ ធ្វើសេចក្តីព្រាងរៀបចំអនុក្រឹត្យ ស្តីពីរបបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។

#### ក.៥ ការពង្រឹងកិច្ចសហប្រតិបត្តិការ

- ក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ បានបន្តពិភាក្សាការងារ ជាមួយក្រសួងការងារថៃ តាមប្រព័ន្ធអនឡាញ។
- អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានរៀបចំ និងចូលរួមអនុវត្តគម្រោងរួមគ្នា រវាងរាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ សម្រាប់ពលករវិលត្រឡប់ ក្នុងដំណាក់កាល នៃការរាតត្បាតដោយជំងឺកូវីដ ១៩ នៅក្នុងខេត្ត បាត់ដំបង សៀមរាប និងបន្ទាយមានជ័យ ។

### ខ. ការបង្ការ ទប់ស្កាត់

#### ខ.១. តាមរយៈការលើកកម្ពស់ការយល់ដឹង

##### ខ.១.១. វេទិកាសាធារណៈ និងភូមិ ឃុំសុវត្ថិភាព

នៅក្នុងខែតុលា ឆ្នាំ២០២០នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ មានសុវត្ថិភាព" និងកម្មវិធីផ្សេងៗ ដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ សាសនិកជន និងប្រជាពលរដ្ឋ សរុបចំនួន

១៦.៨៣២លើក មានអ្នកចូលរួមសរុបចំនួន ៧៧០.៨៣៩នាក់ (ធៀបនឹងខែកញ្ញា មានចំនួន ៥៤៩.៩០៧នាក់ គឺ មានការកើនឡើងចំនួន ២២០.៩៣២នាក់ ស្មើនឹង៤០,១៧% ក្នុងនោះស្ត្រីចំនួន ៣០៨.៥៨១នាក់ ដូចមាន តារាងលម្អិតខាងក្រោម៖

### តារាងទិន្នន័យការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ និងវេទិកាសាធារណៈ

| ល.រ | ក្រសួង ស្ថាប័ន<br>រាជធានី-ខេត្ត | ផ្សព្វផ្សាយ<br>ចំនួន ដង/លើក | ផ្សព្វផ្សាយ<br>ចំនួន មនុស្ស | ផ្សព្វផ្សាយ<br>ចំនួន ស្ត្រី | វេទិកាសាធារណៈ<br>ចំនួន ដង/លើក | វេទិកាសាធារណៈ<br>ចំនួន មនុស្ស | វេទិកាសាធារណៈ<br>ចំនួន ស្ត្រី |
|---|---|---|---|---|---|---|---|
| ក្រសួង ស្ថាប័ន | | | | | | | |
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ៤៦២ | ២២.២៩០ | ១១.៤២៥ | ២៤៩ | ១៣.៥៩៤ | ៦.០២៥ |
| | សរុប ក្រសួង ស្ថាប័ន | ៤៦២ លើក | ២២.២៩០ នាក់ | ១១.៤២៥ នាក់ | ២៤៩ លើក | ១៣.៥៩៤ នាក់ | ៦.០២៥ នាក់ |
| រាជធានី-ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | | | | | | |
| ២ | ខេត្តកណ្ដាល | ៣៣៧ | ៩.៥១២ | ៥.៣៧៨ | ១.០៤១ | ៦៤.៣៨២ | ៣៣.២០៧ |
| ៣ | ខេត្តបាត់ដំបង | ១.៤០២ | ៤៣.១៨០ | ២២.៥០៦ | ១.០៥១ | ២៧.៩២២ | ១៤.៩៥០ |
| ៤ | ខេត្តពោធិ៍សាត់ | ៣៦១ | ៣២.៦៧០ | ១៩.៦១៨ | ១១១ | ៧.០៤៤ | ៣.៤៥១ |
| ៥ | ខេត្តសៀមរាប | ៣៨៣ | ១៨.៣០៧ | ១០.៨៤៥ | ១៤២ | ៤.១៥០ | ២.៤៨៩ |
| ៦ | ខេត្តកំពង់ឆ្នាំង | ១.៣៩២ | ៤៣.២៦៨ | ២៣.៦៣២ | ៤.៦៨១ | ១៥៥.០៩៨ | ៨៣.៨៥៨ |
| ៧ | ខេត្តកំពង់ចាម | ៣.៦៤០ | ២៥៤.៥៩២ | ៣០.៥៥៦ | ២៧២ | ១០.៣១១ | ៥.៣០៧ |
| ៨ | ខេត្តព្រះសីហនុ | ១១ | ៤៥៦ | ២០៣ | | | |
| ៩ | ខេត្តព្រះវិហារ | ១៨០ | ១២.៦៨៦ | ៨.១១៨ | ៦០ | ២.២៤៦ | ១.២៥៦ |
| ១០ | ខេត្តស្វាយរៀង | ០៨ | ៤៨ | ១៦ | ២៩៩ | ១១.៣៨១ | ៦.៤៣៣ |
| ១១ | ខេត្តប៉ៃលិន | ៤៥ | ១.៦០៧ | ២៨៦ | ១៦ | ៧៣៦ | ១៧៨ |
| ១២ | ខេត្តកោះកុង | ២០១ | ៤.៦០០ | ២.៦៧០ | | | |
| ១៣ | ខេត្តកំពត | | | | | | |
| ១៤ | ខេត្តកំពង់ធំ | | | | | | |
| ១៥ | ខេត្តតាកែវ | ៣៤៣ | ១៣.៩៧១ | ៧.៦៩៩ | ៨២ | ៣.០៦០ | ១.៦១៥ |
| ១៦ | ខេត្តក្រចេះ | ៤៨ | ២.៦២៥ | ១.២០៩ | | | |
| ១៧ | ខេត្តកែប | | | | | | |
| ១៨ | ខេត្តកំពង់ស្ពឺ | | | | | | |
| ១៩ | ខេត្តស្ទឹងត្រែង | | | | | | |
| ២០ | ខេត្តរតនគិរី | ៦ | ៧.១១៧ | ៣.៧៤២ | | | |
| ២១ | ខេត្តព្រៃវែង | ១ | ១៨ | ២ | | | |
| ២២ | ខេត្តត្បូងឃ្មុំ | ២ | ៣០២៨ | ១.៧១៤ | | | |
| ២៣ | ខេត្តបន្ទាយមានជ័យ | | | | | | |
| ២៤ | ខេត្តឧត្តរមានជ័យ | ២ | ៦៤៧ | ៧ | | | |
| ២៥ | ខេត្តមណ្ឌលគិរី | ៤ | ២៩៣ | ១៨៦ | | | |
| | សរុប រាជធានី-ខេត្ត | ៨.៣៦៦លើក | ៤៤៨.៦២៥នាក់ | ១៣៨.៣៨៧នាក់ | ៧.៧៥៥លើក | ២៨៦.៣៣០នាក់ | ១៥២.៧៤៤នាក់ |
| | សរុបរួម<br>ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត | ចំនួន<br>១៦.៨៣២ លើក | | ចំនួនមនុស្សសរុប<br>៧៧០.៨៣៩ នាក់ | | ចំនួនស្ត្រី<br>៣០៨.៥៨១ នាក់ | |

### ខ.១.២. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និង ប្រព័ន្ធអេឡិចត្រូនិក

- **ខេត្តសៀមរាប៖** មន្ទីរព័ត៌មានខេត្ត បានធ្វើការផ្សព្វផ្សាយអប់រំ នៅក្នុងកម្មវិធីវិទ្យុ FM ជាតិនគរភ្នំ ១០៣MHz និងទូរទស្សន៍ជាតិខេត្តសៀមរាប ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការជួញដូរមនុស្ស ចំនួន ៣០លើក (ផ្សាយផ្ទាល់ ០៨លើក និងចាក់ផ្សាយឡើងវិញ ២២លើក)។
- **ខេត្តតាកែវ៖** មន្ទីរព័ត៌មានខេត្ត បានផ្សព្វផ្សាយច្បាប់នានាពាក់ព័ន្ធ នឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈវិទ្យុគោកធ្លក សរុបចំនួន ៣០អត្ថបទ និង ៣៨លើក។
- **ខេត្តកំពង់ចាម៖** មន្ទីរព័ត៌មានខេត្ត បានធ្វើការផ្សព្វផ្សាយតាមរយៈវិទ្យុ និងហ្វេសប៊ុក ស្តីពីការផ្តល់សេវាគាំទ្រដល់ពលករក្នុងកំឡុងពេលកូវីដ១៩ ចំនួន ០៨លើក។
- **ខេត្តមណ្ឌលគិរី៖** មន្ទីរធម្មការ និងសាសនាខេត្ត បានផ្សព្វផ្សាយតាមរយៈវិទ្យុជាតិ FM 97MHz ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ក្នុងកម្មវិធី "ព្រះពុទ្ធសាសនា ផ្សាភ្ជាប់សង្គម" ចំនួន ២០លើក។

### ខ.១.៣. ការចូលរួមជាវាគ្មិន ក្នុងកម្មវិធីនានា

- **អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖**
- ឧត្តមសេនីយ៍ទោ កែវ សុវណ្ណារ៉ា ប្រធានក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ បានអញ្ជើញជាគ្រូឧទ្ទេសធ្វើបទបង្ហាញវិធីសាស្ត្រ ៧ចំនុចក្នុងការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ជូនដល់សិក្ខាកាមចំនួន ១០៦នាក់ មកពីស្ថាប័ន និងមន្ទីរពាក់ព័ន្ធ នៅសាលាខេត្តបាត់ដំបង។

## ខ.២. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

### ខ.២.១. ការធ្វើអធិការកិច្ច នឹងពង្រឹងប្រសិទ្ធភាពលើការអនុវត្តការងារ

- **ខេត្តប៉ៃលិន៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះធ្វើអធិការកិច្ចការងារ នៅតាមគ្រឹះស្ថានដែលមានការប្រើប្រាស់កម្លាំងពលកម្មដូចជា សៃឡូ កាស៊ីណូ ឡូតដ្ឋ និងអាហារដ្ឋាន ចំនួន ៨០កន្លែង ដោយរកពុំឃើញមានការកេងប្រវ័ញ្ច និងអំពើជួញដូរកម្លាំងពលកម្មទេ។
- **ខេត្តកំពង់ឆ្នាំង៖** ស្នងការដ្ឋាននគរបាលខេត្ត បានចុះពិនិត្យតាមសិប្បកម្មឡូតដ្ឋចំនួន ០៣កន្លែង មិនឃើញមានករណីកេងប្រវ័ញ្ចកម្លាំងពលកម្មឡើយ។
- **ខេត្តរតនគិរី៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ចុះធ្វើអធិការកិច្ចសាមញ្ញ ០១លើក មិនឃើញមានករណីកេងប្រវ័ញ្ចកម្លាំងពលកម្មឡើយ។
- **ខេត្តស្វាយរៀង៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះធ្វើអធិការកិច្ចការងារតាមគោលដៅសិប្បកម្ម រោងចក្រ សហគ្រាស ចំនួន ០១លើក ស្មើ ០៨គោលដៅ មិនឃើញមានករណីកេងប្រវ័ញ្ចកម្លាំងពលកម្មឡើយ។
- **ខេត្តក្រចេះ៖** មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បានចុះធ្វើអធិការកិច្ចលើការថែទាំចំពោះកុមារនៅមណ្ឌលអង្គការ ចំនួន ០២លើក។

### ខ.២.២. ការគ្រប់គ្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក

- **អគ្គស្នងការដ្ឋាននគរបាលជាតិ**

ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានធ្វើបច្ចុប្បន្នភាពទិន្នន័យប្រចាំខែ ចំពោះពលករចំណាកស្រុកត្រឡប់មកពីក្រៅប្រទេសវិញ ទាំងស្របច្បាប់ និងមិនស្របច្បាប់ សរុបចំនួន ៩៨.០៨១នាក់ លើ ៩៦.៥៩៤នាក់(ស្រី ៤២.៦២៤នាក់) អនីតិជន២.២៧៦នាក់។

- **ស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង** បានធ្វើការបង្ការ ទប់ស្កាត់ពលរដ្ឋខ្មែរ ដែលធ្វើចំណាកស្រុកទៅប្រទេសវៀតណាមដោយខុសច្បាប់បានចំនួន ០៤លើក មនុស្សចំនួន ៣៩នាក់ (ស្រី ១៣នាក់) សមត្ថកិច្ចបានធ្វើកិច្ចសន្យាអប់រំ ណែនាំមិនឱ្យធ្វើចំណាកស្រុកដោយខុសច្បាប់បន្តទៀត។
- **ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង៖** កម្លាំងល្បាតតាមខ្សែបន្ទាត់ព្រំដែន របស់វរនគរបាលការពារ ព្រំដែនគោកវរសេនាតូចលេខ ៨១៧ ៨១៩ ៨២៣ និង៣១០ បានចេញល្បាតតាមបន្ទាត់ព្រំដែនភូមិសាស្ត្ររបស់ខ្លួនបានចំនួន ៥៦លើក ហើយបានប្រទះឃើញពលករឆ្លងដែនខុសច្បាប់ចំនួន ២២៤នាក់ (ស្រី ៧៩នាក់ អនីតិជន ១៨នាក់) បានធ្វើការអប់រំ និងឱ្យត្រឡប់ទៅផ្ទះវិញ។
- **ស្នងការដ្ឋាននគរបាលខេត្តរតនគិរី៖** កម្លាំងល្បាតតាមខ្សែបន្ទាត់ព្រំដែន របស់វរនគរបាលការពារព្រំដែនគោក បានចេញល្បាតតាមបន្ទាត់ព្រំដែនភូមិសាស្ត្ររបស់ខ្លួន ចំនួន ៣២លើក (ព្រំដែនកម្ពុជាវៀតណាម ២៨លើក និងព្រំដែនកម្ពុជា-ឡាវ ០៤លើក) ពុំបានឃើញការលួចឆ្លងដែនខុសច្បាប់ទេ។

**ខ.២.៣. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ**

- **អគ្គស្នងការដ្ឋាននគរបាលជាតិ**

- ស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង ក្រចេះ ពោធិ៍សាត់ បន្ទាយមានជ័យ ព្រៃវែង និងខេត្តរតនៈគិរី បានល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ បានចំនួន ២២លើក។
- ស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង កំពង់ឆ្នាំង និងខេត្តស្ទឹងត្រែង បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ជារកម្ម និងផ្សព្វផ្សាយ ច្បាប់ប្រឆាំងការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម ភោជនីយដ្ឋាន ផ្ទះសំណាក់ សណ្ឋាគារ ម៉ាស្សា ចំនួន ៥០គោលដៅ មនុស្សចូលរួម ៣៥៣នាក់ ស្រី ១៦៩នាក់។

**ខ.២.៤. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស**

- **ក្រសួងមហាផ្ទៃ**

  នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) បានធ្វើសម្ភាសន៍ពលរដ្ឋខ្មែរ និងជនបរទេសដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ចំនួន ៤៣គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ និងបានសាកសួរសុខទុក្ខនារីខ្មែរ ដែលរៀបការរួចហើយទៅរស់នៅសាធារណរដ្ឋកូរ៉េ ដោយបានទំនាក់ទំនងតាមទូរស័ព្ទផ្ទាល់របស់សាមីខ្លួនបានចំនួន ០៧នាក់(រស់នៅជាមួយគ្រួសារសុខសប្បាយជាធម្មតា)។

**ខ.៣. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ**

- **ខេត្តព្រះសីហនុ៖** បន្តសហការជាមួយអង្គការម្លប់តាប៉ាង ធ្វើការទំនាក់ទំនងជាប្រចាំជាមួយបណ្តាញដែលបានដាក់ចំនួន ១.២២៧នាក់ (ម៉ូតូឌុប ក្រុមម៉ូតូកង់បី ផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ ភ្នាក់ងារទេសចរណ៍ និងសហគមន៍) ដើម្បីទប់ស្កាត់ទេសចរណ៍ផ្លូវភេទលើកុមារ។
- **ខេត្តក្រចេះ៖** កុមារមករស់នៅភូមិកុមារកម្ពុជា SOS សរុបចំនួន ៨៩នាក់ (ស្រី ៣៩នាក់)។
- **ខេត្តពោធិ៍សាត់៖** មានមណ្ឌលកុមាររដ្ឋ ០១ កុមារចំនួន ០៧នាក់ (ស្រី ០៤នាក់) និងមណ្ឌលកុមារអង្គការ ១២ កុមារចំនួន ១៧៦នាក់ (ស្រី ៧៩នាក់)។
- **ខេត្តឧត្តរមានជ័យ៖** មានមណ្ឌលកុមារអង្គការ ០៣ កុមារចំនួន ៩៦នាក់ (ស្រី ៦៤នាក់)។

- **ខេត្តព្រះវិហារ៖** មានមណ្ឌលកុមាររដ្ឋ ០១ កុមារចំនួន ៩៧នាក់ (ស្រី ៤០នាក់) និងមណ្ឌលកុមារអង្គការ ០៦ (ស្តេប ០១ កុមារកំព្រាក្នុងក្តីសង្ឃឹមថ្មី ០១ និងវិហារសាសនាគ្រីស្ទដំណឹងល្អ ០៤) មានកុមារសរុបចំនួន ១៦០នាក់ (ស្រី ៧៩នាក់)។
- **ខេត្តតាកែវ៖** មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត សហការជាមួយអង្គការដៃគូ បានបើកវេទិកាពិគ្រោះយោបល់ចូលរួមអនុវត្តអនុសញ្ញា ស្តីពីសិទ្ធិកុមារ ចំនួន ០២លើក មានអ្នកចូលរួមសរុប ៦០នាក់ (ស្រី ៤៥នាក់)។

### ខ.៤. ការកាត់បន្ថយភាពងាយរងគ្រោះ តាមរយៈការផ្តល់ប័ណ្ណព្រំដែនដល់មុខសញ្ញាងាយរងគ្រោះ

- រដ្ឋបាលខេត្តចំនួន០២ គឺខេត្តបាត់ដំបង និងខេត្តប៉ៃលិន ដែលមានច្រកប៉ុស្តិ៍អន្តរជាតិនៅតាមព្រំដែន បានផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ (Border Pass) សរុបចំនួន ៥៥៦ប័ណ្ណ ដល់ពលរដ្ឋខ្មែរដែលរស់នៅក្នុងខេត្តជាប់ព្រំដែន មាន៖
  - ខេត្តបាត់ដំបង ចំនួន ៤៤៣ ប័ណ្ណ
  - ខេត្តប៉ៃលិន ចំនួន ១១៣ ប័ណ្ណ។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### គ.១. ការងារអនុវត្តច្បាប់

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះទទួលបានពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត។

#### គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន ០៩ករណី(ធៀបនឹងខែកក្កដា មានចំនួន ១២ករណី ថយចុះចំនួន ០៣ករណី)ស្មើនឹង ២៥% ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូង ចំនួន ១២នាក់(ស្រី ០៤នាក់) ក្នុងនោះជនសង្ស័យជាអនីតិជន ០២នាក់។

សង្គ្រោះជនរងគ្រោះ ចំនួន ៥០នាក់ មាន៖ អាយុក្រោម១៥ឆ្នាំ ០៨នាក់ អាយុ១៥-១៧ឆ្នាំ ០៩នាក់ និងអាយុពី១៨ឆ្នាំឡើង ៣៣នាក់ (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច ០៦នាក់ និងប្រគល់ឱ្យគ្រួសារ ៤៤នាក់) ក្នុងនោះមានបែកជា៖

១. ករណីអំពើជួញដូរមនុស្ស

បង្ក្រាបបាន ០២ករណី/០១ករណី (កើនឡើង ០១ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ០៣នាក់ (ស្រី ០២នាក់)។ សង្គ្រោះជនរងគ្រោះចំនួន ៣៨នាក់ មាន៖ អាយុក្រោម១៥ឆ្នាំ ០១នាក់ អាយុ១៥-១៧ឆ្នាំ ០៦នាក់ អាយុ១៨ឆ្នាំឡើង ៣១នាក់ (ប្រគល់ឱ្យគ្រួសារ ៣៨នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ |
|---|---|---|---|
| -ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច | ០១ | ០១ | ០២ |
| -អំពើនាំឆ្លងដែន | ០១ | ៣៧ | ០១ |
| *សរុប* | *០២ ករណី* | *៣៨ នាក់* | *០៣ នាក់* |

២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន ០៧ករណី/១១ករណី (ថយចុះ ០៤ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ០៩នាក់(ស្រី ០២នាក់) អនីតិជន ០១នាក់។ សង្គ្រោះជនរងគ្រោះចំនួន ១២នាក់ មានៈ អាយុក្រោម១៥ឆ្នាំ ០៧នាក់ អាយុ ១៥-១៧ឆ្នាំ ០៣នាក់ និងអាយុ១៨ឆ្នាំឡើង ០២នាក់ (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច ០៦នាក់ និងប្រគល់ឱ្យគ្រួសារ ០៦នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ |
|---|---|---|---|
| -សញ្ចារកម្ម (មានអនីតិជន)<br>-អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០១<br>០៦ | ០៦<br>០៦ | ០៣<br>០៦ |
| *សរុប* | *០៧ នាក់* | *១២ នាក់* | *០៩ នាក់* |

## **ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ**

### **ឃ.១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និង ផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ**

ឃ.១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់

- ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត

  ស្នងការដ្ឋាននគរបាលខេត្ត ចំនួន ០២ បានទទួល និងសម្ភាសពលករខ្មែរ ដែលអាជ្ញាធរបរទេសចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ និងច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-វៀតណាម ចំនួន ២៨លើក មនុស្សចំនួន ៣៤៨នាក់(ស្រី ១៣៦នាក់ អនីតិជន ២៥នាក់) ក្នុងនោះមានៈ

  - ខេត្តបន្ទាយមានជ័យ ចំនួន ២៤លើក មនុស្សចំនួន ៣៣៥នាក់ (ស្រី ១៣០នាក់) អនីតិជនចំនួន ២៤នាក់។
  - ខេត្តកោះកុង ចំនួន ០៤លើក មនុស្សចំនួន ១៣នាក់ (ស្រី ០៦នាក់) អនីតិជនចំនួន ០១នាក់។

# **III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល**

## **ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា**

### **ក.១. ការងារបណ្តុះបណ្តាល**

ក.១.១.ការបណ្តុះបណ្តាលក្នុងប្រទេស

តារាងវគ្គបណ្តុះបណ្តាល

| សកម្មភាពរៀបចំវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|
| ខេត្តព្រះសីហនុៈ លេខាធិការដ្ឋាន គ.ជ.ប.ជ បើកវគ្គបណ្តុះបណ្តាល ពង្រឹងសមត្ថភាពដល់ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅស្រុកព្រៃនប់ និងស្រុកកំពង់សីលា។ | ០២ | ១២៩ | ៣៩ |

| | | | |
|---|---|---|---|
| **ខេត្តកំពត៖** លេខាធិការដ្ឋាន គ.ខ.ប.ជ បានបើកវគ្គបណ្តុះបណ្តាល ស្តីពីទេសន្តរប្រវេសន៍ការងារ និងការជ្រើសរើសពលករប្រកបដោយសមធម៌ ដែលឧបត្ថមគាំទ្រដោយរដ្ឋាភិបាលអូស្ត្រាលី តាមរយៈគម្រោងTRIANGLE នៅអាស៊ាន នៃអង្គការ ILO។ | ០៣ | ១៤៥ | ៥៤ |
| **ខេត្តបាត់ដំបង៖** លេខាធិការដ្ឋាន គ.ខ.ប.ជ បើកវគ្គបណ្តុះបណ្តាលគោលការណ៍ណែនាំ ស្តីពី បែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប រយៈពេល ៣ថ្ងៃ។ | ០១ | ៩០ | ០ |
| **ខេត្តស្វាយរៀង៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយក្រុមហ៊ុនសហគ្រាស បើកវគ្គបណ្តុះបណ្តាល ស្តីពីច្បាប់ការងារ និងគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ។ | ០៤ | ៧៦ | ៤៣ |
| **ខេត្តកំពង់ចាម៖** | | | |
| - លេខាធិការដ្ឋាន គ.ខ.ប.ជ បើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីយន្តការរបស់ គ.ខ.ប.ជ នៅក្រុងកំពង់ចាម កងមាស និងស្រុកស្រីសន្ធរ។ | ០១ | ១២០ | ៣៣ |
| - មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បើកវគ្គបណ្តុះបណ្តាលលើកកម្ពស់ និងការពារសិទ្ធិការងារពលករចំណាកស្រុកដែលមានជំនាញទាបទៅប្រទេសថៃ។ | ០១ | ២១ | ១៤ |
| **ខេត្តកំពង់ធំ៖** លេខាធិការដ្ឋាន គ.ខ.ប.ជ សហការជាមួយអង្គការ IOM បើកវគ្គបណ្តុះបណ្តាល ស្តីពីការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព នៅក្នុងស្រុកស្ទោង។ | ០២ | ៨៧ | ០ |
| **ខេត្តក្រចេះ៖** ស្នងការដ្ឋាននគរបាលខេត្ត សហការជាមួយអង្គការសម្ព័ន្ធចាប់ដៃ បើកវគ្គបណ្តុះបណ្តាល ជំនាញប្រឆាំងការជួញដូរមនុស្ស ដល់នគរបាលជំនាញប្រឆាំងការជួញដូរមនុស្ស រយៈពេល ០៣ថ្ងៃ។ | ០១ | ៣១ | ១១ |
| **ខេត្តសៀមរាប៖** | | | |
| - លេខាធិការដ្ឋាន គ.ខ.ប.ជ សហការជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងអង្គការ APLE បើកវគ្គបណ្តុះបណ្តាលស្តីពី ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស ដល់ក្រុមយុវជនរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត នៅស្រុកអង្គរធំ អង្គរជុំ វ៉ារិន និងស្រុកក្រឡាញ់។ | ០៤ | ២៣៣ | ១៤២ |
| - លេខាធិការដ្ឋាន គ.ខ.ប.ជ សហការជាមួយអង្គការមូលនិធិអេ២១ បើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពការអនុវត្តតួនាទីភារកិច្ចក្រុមការងារ ថ្នាក់ក្រុង ស្រុក និងឃុំ សង្កាត់ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងកិច្ចការពារកុមារពីការរំលោភបំពាន នៅស្រុកស្វាយលើ ជីក្រែង វ៉ារិន និងស្រុកស្រីស្នំ។ | ០៤ | ១៨៨ | ៧០ |
| - មន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងសហការជាមួយ អង្គការមូលនិធិអេ២១ បើកវគ្គបណ្តុះបណ្តាលស្តីពី ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចកុមារ ដល់លោកគ្រូ អ្នកគ្រូ។ | ០១ | ៤៥ | ១៦ |
| - ក្រុមការងារអនុវត្តច្បាប់ខេត្ត បើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព ស្តីពីការអនុវត្តតួនាទីភារកិច្ចការពារកុមារពីការរំលោភបំពាន។ | ០១ | ៤៥ | ១៩ |
| **ខេត្តព្រះវិហារ៖** ស្នងការដ្ឋាននគរបាលខេត្ត សហការជាមួយអង្គការសម្ព័ន្ធចាប់ដៃ បើកវគ្គបណ្តុះបណ្តាល ស្តីពីនីតិវិធីស៊ើបអង្កេតករណីជួញដូរមនុស្ស និងក្រមសីលធម៌ ក្នុងការសម្ភាសកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ | ០១ | ២៧ | ០៨ |

| | | | |
|---|---|---|---|
| ខេត្តត្បូងឃ្មុំ៖ ស្នងការដ្ឋាននគរបាលខេត្ត បើកវគ្គបណ្តុះបណ្តាល ស្តីពីនីតិវិធីស៊ើបអង្កេតករណីជួញដូរមនុស្ស និងក្រមសីលធម៌ក្នុងការសម្ភាសកំណត់អត្តសញ្ញាណជនរងគ្រោះ។ | ០១ | ០ | ០ |
| សរុប | ២៧ វគ្គ | ១.២៣៧ នាក់ | ៤៤៩ នាក់ |

### ក.២. សិក្ខាសាលា

#### ក.២.១.សិក្ខាសាលាក្នុងប្រទេស

| សកម្មភាពរៀបចំសិក្ខាសាលា | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|
| អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ សហការជាមួយអង្គការសម្ព័ន្ធចាប់ដៃ រៀបចំសិក្ខាសាលាថ្នាក់ជាតិស្តីពី សេវា គាំទ្រជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅភោជនីយ៍ដ្ឋានទន្លេបាសាក់២។ | ០១ | ៨៥ | ២៥ |
| ខេត្តកំពង់ចាម៖ លេខាធិការដ្ឋាន គ.ខ.ប.ជ រៀបចំសិក្ខាសាលាស្តីពី ការចែករំលែកបទពិសោធន៍ និងពង្រឹងការសហការរវាងជនបង្គោលមូលដ្ឋាន និងអង្គការសង្គមស៊ីវិល លើវិស័យសិទ្ធិការងារ របស់ពលករចំណាកស្រុក នៅសណ្ឋាគារពមកពា។ | ០១ | ៣៩ | ០ |
| ខេត្តព្រៃវែង៖ លេខាធិការដ្ឋាន គ.ខ.ប.ជ រៀបចំសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីសុខភាពទេសន្តរប្រវេសន៍ នៅសាលាខេត្ត។ | ០១ | ០ | ០ |
| សរុប | ០៣ វគ្គ | ១២៤ នាក់ | ២៥ នាក់ |

## ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ខ.១ កិច្ចប្រជុំ ជាអន្តរជាតិនៅក្នុងប្រទេស និងក្រៅប្រទេស

- ➢ កិច្ចប្រជុំក្នុងប្រទេស
  - ▪ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)
    - លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ៖
      - ○ បានដឹកនាំកិច្ចប្រជុំពិភាក្សា ពាក់ព័ន្ធស្ថានភាព និងការគ្រប់គ្រងពលករទេសន្តរប្រវេសន៍ ដែលងាយរងគ្រោះក្នុងកំឡុងពេលរាតត្បាតជំងឺកូវីដ១៩ និងតាមដាន ត្រួតពិនិត្យការអនុវត្តគម្រោងផែនការរួមគ្នា រវាងរាជរដ្ឋាភិបាលកម្ពុជា និងយូអិន នៅសាលប្រជុំសាលាខេត្តបន្ទាយមានជ័យ។
      - ○ បានដឹកនាំកិច្ចប្រជុំ "**ដើម្បីផ្តល់ធាតុចូលលើសេចក្តីព្រាងឯកសារទស្សនទាន ស្តីពីការរៀបចំច្រកធ្វើដំណើរក្នុងអាស៊ាន ( ASSEAN Travel Corridor Arrangement)**" អ្នកចូលរួមចំនួន ៣៣នាក់ (ស្រី ០៩នាក់) នៅសាលប្រជុំ ទីស្តីការក្រសួងមហាផ្ទៃ។
      - ○ បានដឹកនាំកិច្ចប្រជុំពិភាក្សា ស្តីពីស្ថានភាពរបស់ប្រជាជនចំណាកស្រុកដែលងាយរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងបញ្ហាសុខភាពក្នុងតំបន់ជាប់ព្រំដែន ខេត្តស្ទឹងត្រែង នៅសាលប្រជុំសាលាខេត្តស្ទឹងត្រែង។
      - ○ បានដឹកនាំកិច្ចប្រជុំពិភាក្សា ចំនួន ០២លើក ស្តីពីការធ្វើចំណាកស្រុក ការជួញដូរមនុស្ស និងបញ្ហាសុខភាព របស់ប្រជាជន នៅសាលប្រជុំសាលាស្រុកសៀមប៉ាង និងស្រុកឆែប ខេត្តព្រះវិហារ។

- o បានដឹកនាំកិច្ចប្រជុំពិភាក្សា ស្តីពីការរៀបចំរបាយការណ៍ រវាងក្រុមជំនួយកិច្ចការទាំង៦ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដើម្បីឆ្លើយតបសហរដ្ឋអាមេរិក អំពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅក្នុងប្រទេសកម្ពុជា នៅសាលប្រជុំ គ.ជ.ប.ជ។
- o បានដឹកនាំកិច្ចប្រជុំពិភាក្សា ជាមួយអង្គការសម្ព័ន្ធមិនមែនរដ្ឋាភិបាលប្រឆាំងការជួញដូរមនុស្ស នៅកម្ពុជា ដើម្បីធ្វើបទបង្ហាញលទ្ធផលនៃការសិក្សាស្រាវជ្រាវ ស្តីពីតម្រូវការ និងការសិក្សាជាមូលដ្ឋាន សម្រាប់កុមារចំណាកស្រុកកម្ពុជាដែលកំពុងរស់នៅប្រទេសថៃ (រៀននៅសាលារៀនប្រទេសថៃ) នៅសាលប្រជុំ គ.ជ.ប.ជ។

**ខ.២. ការជំនួបពិភាក្សាការងារ**

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)
  - លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានជំនួបពិភាក្សាការងារៈ
    - o ជាមួយតំណាងស្ថានទូតអាមេរិក និង USAID អំពីលទ្ធភាពនៃការជួយ គាំទ្ររបស់សហរដ្ឋអាមេរិក ក្នុងការលើកកម្ពស់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ក្នុងការឆ្លើយតបទៅនឹងការស្តារ និងលើកកម្ពស់ចំណាត់ថ្នាក់នៅឆ្នាំបន្តបន្ទាប់ ដើម្បីសម្រេចបានលទ្ធផលល្អប្រសើរ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅកម្ពុជា នៅសាលប្រជុំ គ.ជ.ប.ជ។
    - o ជាមួយអង្គការចាប់ដៃ ដើម្បីពិភាក្សាការងារក្នុងការរៀបចំសិក្ខាសាលា នៅសាលប្រជុំ គ.ជ.ប.ជ។
    - o ជាមួយអង្គការ អាយអូអឹម ដើម្បីចុះតាមដាន ត្រួតពិនិត្យផែនការសកម្មភាព ក្នុងការអនុវត្តគម្រោងរួមគ្នា រវាងរាជរដ្ឋាភិបាលកម្ពុជា និងយូអិន នៅស្រុកកំរៀង ខេត្តបាត់ដំបង។
    - o ជាមួយអង្គការ អាយអូអឹម ដើម្បីចុះតាមដាន ត្រួតពិនិត្យផែនការសកម្មភាព ក្នុងការអនុវត្តគម្រោងរួមគ្នា រវាងរាជរដ្ឋាភិបាលកម្ពុជា និងយូអិន នៅស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។
    - o ជាមួយតំណាងអង្គការមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន ស្តីពីការធ្វើចំណាកស្រុក ការជួញដូរមនុស្ស និងបញ្ហាសុខភាព របស់ប្រជាជន នៅស្រុកសៀមប៉ាង ខេត្តព្រះវិហារ។

## គ. ការងារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ ២៥លើក មានអ្នកចូលរួមសរុប ៨០២នាក់ (ស្រី ២០៩នាក់) ក្នុងនោះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២លើក-និងលេខាធិការដ្ឋានរាជធានី-ខេត្ត ចំនួន ២៥លើក។ (ឧបសម្ព័ន្ធ១)

# IV. ការសន្និដ្ឋានវាយតម្លៃ

## ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឲ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ ០៤ចំណុច និងវិធានការ ០៦ចំណុច របស់

សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួងស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

## ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជាៈ

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការផ្ញើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឲ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

## គ. សំណូមពរ

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឲ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឲ្យលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ផ្តល់របាយការណ៍ឲ្យបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

## ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឲ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅខែវិច្ឆិកា ឆ្នាំ ២០២០

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឲ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាពជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដេកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាង

ទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឲ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៨. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឲ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ។

៩. បន្តរៀបចំវិធានការ "គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១០. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១១. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

១២. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ............ខែ........ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី........ខែ........ឆ្នាំ២០២០

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ-ប៊ុនអេង**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារគ.ជ.ប.ជ

-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

"ដើម្បីជូនជ្រាប"

-ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

## តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ២៥លើក) មនុស្សចំនួន ៨០២នាក់ (ស្រី ២០៩នាក់)

| ស្ថាប័នសម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | ▪ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ<br>-បានដឹកនាំគណៈប្រតិភូអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងក្រុមការងារអង្គការ មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន ចុះសួរសុខទុក្ខ និងចុះសិក្សានៅតំបន់ជាប់ព្រំដែន នៃស្រុកសៀមប៉ាង និងស្រុកឆែន ខេត្តព្រះវិហារ អំពីស្ថានភាពចំណាកស្រុកឆ្លងដែន ការជួញដូរមនុស្ស និងបញ្ហាសុខភាពរបស់ប្រជាជន។<br>-បានអញ្ជើញជាអធិបតីភាព ក្នុងវេទិកាសាធារណៈដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីគោលនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់ រាជរដ្ឋាភិបាលកម្ពុជា ចំនួន០៤លើក ដោយមានការចូលរួមពីក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានក្រុង អភិបាលរងខេត្ត អភិបាលរងក្រុង តំណាងមន្ទីរនានា អាជ្ញាធរ ដែនដីមានសមត្ថកិច្ច ស្នងការរងនគរបាល មេបញ្ជាការរងរាជអាវុធហត្ថស្រុក ក្រុមប្រឹក្សា ឃុំ សង្កាត់ មន្ត្រីពាក់ព័ន្ធ និងប្រជាពលរដ្ឋ ក្នុងសង្កាត់កំពង់ឆ្នាំងចំនួន១០០នាក់ សង្កាត់ប្អេរចំនួន៥៦នាក់ សង្កាត់ផ្សារឆ្នាំងចំនួន៦៦នាក់ និងសង្កាត់ខ្សាមចំនួន៦៨នាក់ ខេត្តកំពង់ឆ្នាំង។<br>▪ លោកជំទាវវេជ្ជបណ្ឌិត ឧត្តមសេនីយ៍ឯក ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ<br>- បានអញ្ជើញចូលរួមកិច្ចប្រជុំសិក្ខាសាលាពិគ្រោះយោបល់លើការអនុវត្តគោលនោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព ឯកឧត្តម ញឹក វណ្ណារ៉ា រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅសណ្ឋាគារ កាំបូឌីយ៉ាណា អ្នកចូលរួមចំនួន៦០នាក់ ស្រី១០នាក់។<br>- បានអញ្ជើញដឹកនាំកិច្ចប្រជុំប្រមូលធាតុចូលនៃជំហរកម្ពុជា សម្រាប់លើកក្នុងកិច្ចប្រជុំកំពូលអាស៊ាន នៅសាលប្រជុំ គ.ជ.ប.ជ។<br><br>▪ **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**<br>- លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ៣២ច្បាប់ លិខិតចូល ១៧ច្បាប់។<br>- លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ១៩ច្បាប់ លិខិតចូល ១១ច្បាប់។<br>- រៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុ រាល់ពេលប្រជុំ។<br>- បូកសរុបរបាយការណ៍ប្រចាំសប្តាហ៍ និងខែតុលា ឆ្នាំ២០២០ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- បូកសរុបរបាយការណ៍ខែតុលា ឆ្នាំ២០២០ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ |

- ប្រមូលរបាយការណ៍ពីអន្តរក្រសួង ស្ថាប័ន និងរាជធានី/ខេត្តទាំង២៥។
- រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមកិច្ចប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។
- ចងក្រងព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលក្នុងបណ្ណសារវីគី។
- ស្រាវជ្រាវព័ត៌មានពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ពីមជ្ឈដ្ឋានផ្សេងៗ ជាពិសេសព័ត៌មានដែលចុះផ្សាយ នៅក្នុងបណ្តាញសង្គម និងគេហទំព័រនានា។
- Scan & Uploaded ឯកសារចូលក្នុងបណ្ណសារនៃប្រព័ន្ធ wiki បានចំនួន ១១៥ច្បាប់។
- អាប់ឡូតរូបភាពសកម្មភាព គ.ជ.ប.ជ ចូលបណ្ណាល័យរូបភាពក្នុងប្រព័ន្ធអ៊ិនធើណេត wiki បានចំនួន ២៤សកម្មភាព។

▪ **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់**

- បានរៀបចំកិច្ចប្រជុំពិភាក្សាពិគ្រោះ និងផ្តល់យោបល់លើទម្រង់នៃរបាយការណ៍ដើម្បីដាក់បញ្ចូលក្នុង Database អ្នកចូលរួមចំនួន០៥នាក់។
- បានរៀបចំកិច្ចប្រជុំពិភាក្សាពិគ្រោះ និងផ្តល់យោបល់លើមេរៀនទម្រង់នៃអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ច សម្រាប់យកទៅបង្រៀន និងធ្វើបទបង្ហាញជូនដល់សិក្ខាកាមជាកងកម្លាំងមួកខៀវកម្ពុជា អ្នកចូលរួមចំនួន០៥នាក់។

▪ **ក្រុមជំនួយកិច្ចការពារជនរងគ្រោះ៖**

- ឯកឧត្តម អគ្គលេខាធិការរង បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមការងារបច្ចេកទេស OCSE ដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនការសកម្មភាពឆ្លើយតបទៅនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមប្រព័ន្ធអនឡាញ នៅសាលប្រជុំសាលាខេត្តកំពត។
- លោកប្រធានក្រុមការងារបានចូលរួមសិក្ខាសាលាពិគ្រោះយោបល់បញ្ចប់សេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីសុខភាពជនអន្តោប្រវេសន៍ អ្នកចូលរួមចំនួន ៦០នាក់ នៅសាលប្រជុំសាលាខេត្តព្រៃវែង។

▪ **ក្រុមជំនួយកិច្ចការយុត្តិធម៌**

- បានរៀបចំកិច្ចប្រជុំជាមួយក្រុមជំនួយកិច្ចការទាំង៦ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដើម្បីពិនិត្យផ្ទៀងផ្ទាត់លទ្ធផលការងាររបស់ខ្លួនដែលទទួលបានពីក្រុមជំនាញអន្តរក្រសួង ស្ថាប័នទាំង៦ ប្រចាំត្រីមាសទី៣ ឆ្នាំ២០២០ និងត្រៀមឆ្លើយតបតាមអនុសាសន៍ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២០-២០២១ ទាំង១៧ចំណុចរបស់អាមេរិក តាមវិស័យពាក់ព័ន្ធរៀងៗខ្លួន នៅសាលប្រជុំ គ.ជ.ប.ជ។

▪ **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ**

- បានចូលរួមសិក្ខាសាលា ស្តីពីទិវាភាពជាអ្នកដឹកនាំឆ្នាំ២០២០ ក្រោមប្រធានបទ "ការបង្កើតទម្លាប់ធ្វើការងារឱ្យបានខ្លាំងក្លា និងមានប្រសិទ្ធភាពខ្ពស់" នៅទីស្តីការក្រសួងកិច្ចការនារី។

| លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ១៣លើក អ្នកចូលរួមសរុបចំនួន ៣៨២នាក់ (ស្រី ១៩៩នាក់) | |
|---|---|
| ខេត្តកណ្ដាល | - ក្រុមការងារក្រុង-ស្រុក បានប្រជុំប្រចាំខែ ចំនួន ០៦លើក អ្នកចូលរួមចំនួន១៦៣នាក់ ស្រី១១៣នាក់។ |
| ខេត្តសៀមរាប | - លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានរៀបចំកិច្ចប្រជុំប្រចាំខែតុលា ឆ្នាំ២០២០ ចំនួន០១លើក អ្នកចូលរួមចំនួន៥៥នាក់ ស្រី៣២នាក់។<br>- ក្រុមការងារទាំង៦ បានចូលរួមកិច្ចប្រជុំកំពូលសកល ស្ដីពីសេរីភាពពីអំពើជួញដូរមនុស្ស (Global Freedom Summit) រៀបចំដោយអង្គការមូលនិធិអេ២១។ |
| ខេត្តរតនគិរី | - លេខាធិការដ្ឋា គ.ខ.ប.ជ ខេត្ត បានរៀបចំកិច្ចប្រជុំបូកសរុបរបាយការណ៍១០ខែ ឆ្នាំ២០២០ ចំនួន០១លើក អ្នកចូលរួមចំនួន១១នាក់ ស្រី០៤នាក់។ |
| ខេត្តព្រះវិហារ | - គ.ខ.ប.ជ ខេត្ត និងក្រុមការងារ បានប្រជុំការងារពាក់ព័ន្ធចំនួន០៣លើក អ្នកចូលរួមចំនួន៧៧នាក់ ស្រី១៩នាក។ |
| ខេត្តក្រចេះ | - លេខាធិការដ្ឋា គ.ខ.ប.ជ ខេត្ត បានរៀបចំកិច្ចប្រជុំបូកសរុបរបាយការណ៍១០ខែ ឆ្នាំ២០២០ ចំនួន០១លើក អ្នកចូលរួមចំនួន៣៦នាក់ ស្រី២២នាក់។ |
| ខេត្តតាកែវ | - លេខាធិការដ្ឋា គ.ខ.ប.ជ ខេត្ត បានរៀបចំកិច្ចប្រជុំបូកសរុបរបាយការណ៍១០ខែ ឆ្នាំ២០២០ ចំនួន០១លើក អ្នកចូលរួមចំនួន៣៤នាក់ ស្រី០៩នាក់។ |